# សេចក្តីប្រកាសព័ត៌មាន

## កម្មវិធីផ្តល់ថវិកាជំនួយ និងវគ្គបណ្តុះបណ្តាល ដើម្បីលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម ឱ្យធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( E-COMMERCE) នៅកម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០៖** សហគ្រាសធុនតូច និងមធ្យមចំនួន ១២៥ នឹងទទួលបានថវិកាជំនួយ និងការបណ្តុះបណ្តាលអំពីរបៀបធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការវិនិយោគថ្មីក្នុងទឹកប្រាក់ចំនួន ៥០០.០០០ ដុល្លារអាមេរិក ដែលផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការឧបត្ថម្ភរបស់កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម ( EIF) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។

មូលនិធិនេះនឹងផ្តល់ការគាំទ្រដល់ការបណ្តុះបណ្តាលបណ្តុះគំនិតអាជីវកម្ម និងគំនិតផ្តួចផ្តើមបែបនវានុវត្តន៍ និងកម្មវិធីផ្តល់ថវិកាគាំទ្រខ្នាតតូចរយៈពេល ០៦ ខែ ដើម្បីជួយសហគ្រាសធុនតូច និងមធ្យមក្នុងការផ្លាស់ប្តូរទៅប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក លក់ផលិតផល និងសេវាកម្មតាមប្រព័ន្ធអនឡាញ និងជួយដល់សហគ្រាសមួយចំនួន ដែលលក់ផលិតផល និងសេវាកម្មទៅឱ្យអតិថិជននៅក្រៅប្រទេស តាមរយៈថ្នាលបច្ចេកវិទ្យាថ្មីមួយ ( B2B2C Marketplace ) ដែលកំពុងបង្កើតឡើងដោយក្រសួងពាណិជ្ជកម្ម។ ចំនួនកូតាត្រូវបានកំណត់ និងបម្រុងទុកសម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលមានម្ចាស់កម្មសិទ្ធិជាស្ត្រី និងយុវជន និងសហគ្រាសដែលមានទីតាំងស្ថិតនៅខាងក្រៅទីក្រុងភ្នំពេញ។

គំនិតផ្តួចផ្តើមនេះត្រូវបានបង្កើត និងអនុវត្តរួមគ្នាដោយ ក្រសួងពាណិជ្ជកម្ម ( MOC ) និង UNDP ដែលជាសមាសភាគមួយដ៏សំខាន់នៃគម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា ហៅថា Go4eCAM ដែលមានគោលបំណងក្នុងការបង្កើនឱកាសទាំងក្នុងស្រុក និងអន្តរជាតិដល់សហគ្រាសធុនតូច និងមធ្យម តាមរយៈគំនិតផ្តួចផ្តើមឌីជីថលភាវូបនីយកម្ម ដើម្បីបង្កើតការងារថ្មីឱ្យបានច្រើនជាង ១០,០០០ ត្រឹមឆ្នាំ២០២២ ដែលជាគោលដៅគម្រោង Go4eCAM។

វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិកនៅកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំង នៅក្នុងទសវត្សចុងក្រោយនេះ ហើយការគាំទ្របន្ថែមទាំងនេះត្រូវបានផ្តល់ក្នុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដែលបានជំរុញឱ្យអាជីវកម្មកាន់តែច្រើនងាកទៅប្រើប្រាស់ប្រព័ន្ធអនឡាញ។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងឌីជីថលភាវូបនីយកម្មត្រូវបានចាត់ទុកថាមានតួនាទីសំខាន់ ដើម្បីជួយឱ្យមានការស្តារសេដ្ឋកិច្ចឡើងវិញឱ្យបានពេញលេញ ឆាប់រហ័ស និងប្រកបដោយចីរភាពសម្រាប់កម្ពុជា។

កាលពីពេលថ្មីៗ នេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងពាណិជ្ជកម្មបានពន្លឿនកិច្ចខិតខំប្រឹងប្រែងសំដៅពង្រឹងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងក្របខ័ណ្ឌគតិយុត្ត ដែលគ្រប់គ្រងលើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា ដូចជា ការអនុម័តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិកកាលពីឆ្នាំ២០១៩ អនុក្រឹត្យសម្រួលដល់ការចុះបញ្ជីអាជីវកម្មដែលផ្តោតលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ក្នុងន័យការពារសិទ្ធិអ្នកទិញទំនិញតាមប្រព័ន្ធអនឡាញ និងអាជីវកម្មនានា ក៏ដូចជាយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលទើបតែបានសម្ពោធដាក់ឲ្យប្រើប្រាស់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ថ្មីៗផងដែរ។

ជាការគាំទ្រដល់ការឆ្លើយតបរបស់កម្ពុជាចំពោះជំងឺកូវីដ-១៩ UNDP កំពុងធ្វើការងារដើម្បីកសាងជំនាញបុគ្គលិកឡើងវិញ ផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមចំនួន ១.០០០ ដើម្បីឱ្យពួកគេអាចឈានជើងចូលទៅក្នុងទីផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងជំរុញឱ្យមានការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទូទាំងប្រទេស តាមរយៈយុទ្ធនាការស្វែងរកការគាំទ្រ ដើម្បីកសាងបរិយាកាសគតិយុត្តឱ្យបានរឹងមាំ ដោយមានការគាំទ្រនៃរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី។

**ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** មានប្រសាសន៍ថា «គម្រោង Go4eCAM ត្រូវបានប្រកាសចាប់ផ្តើមអនុវត្តចំពេលជួនគ្នាជាមួយនឹងការអនុម័តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការប្រកាសដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ គម្រោងនេះនឹងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនផ្សេងទៀត ដូចជា បង្កើនផលិតភាព នវានុវត្តន៍ ការពង្រីកអាជីវកម្ម ព្រមទាំងការបង្កើតការងារនៅកម្ពុជា។»

**លោក Nick Beresford អ្នកតំណាងនិវេសនដ្ឋាន UNDP ប្រចាំកម្ពុជា** បានលើកឡើងថា «យុទ្ធសាស្ត្រស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកថ្មីរបស់កម្ពុជា គួបផ្សំនឹងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ និងជំរុញឱ្យមានការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងសង្គមទាំងមូល ជាពិសេសក្នុងចំណោមក្រុមដែលមានឱកាសតិចតួច អាចជាយុទ្ធសាស្ត្រដ៏សំខាន់ដើម្បីជំរុញកំណើនប្រកបដោយបរិយាប័ន្នក្រោយពីកូវីដ-១៩។ ការវិនិយោគប្រកបដោយបរិយាប័ន្នលើធនធានមនុស្ស ការអភិវឌ្ឍជំនាញ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់គ្រប់គ្នា គឺជាអ្វីដែលមានសារៈសំខាន់ជាចាំបាច់បំផុតនាពេលនេះ។»

«វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺមានសន្ទុះយ៉ាងខ្លាំងជាពិសេសដោយការប្រែក្លាយពីអាជីវកម្មធម្មតាទៅជាអាជីវកម្មអនឡាញ ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩។ ក្នុងនាមជាដៃគូរបស់កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (EIF) និងតាមរយៈគម្រោងនានារបស់យើងដែលគាំទ្រដល់ការពន្លឿនផ្នែកច្បាប់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រទេសអូស្ត្រាលីបានផ្តល់ជាទស្សនទាន និងជំនាញសំខាន់ៗ មួយចំនួនដល់យុវជនកម្ពុជា ដើម្បីប្រកួតប្រជែងក្នុងសេដ្ឋកិច្ចថ្មីនេះ ដោយធានាថា វិស័យឌីជីថលនាពេលអនាគតរបស់កម្ពុជានឹងត្រូវបានរីកចំរើនប្រកបដោយបរិយាប័ន្ន។» នេះជាការលើកឡើងរបស់ **ឯកឧត្តម Kang Pablo ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា។**

**លោកបណ្ឌិត Ratnakar Adhikari នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន EIF ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក** បានលើកឡើងថា «កម្ពុជា គឺជាប្រទេសមួយដែលមានសក្តានុពលខ្ពស់ក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ យុទ្ធសាស្ត្រស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលនៅក្រោមការគាំទ្រពី EIF ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ នេះ ដោយមានការដាក់ចេញនូវផែនការសកម្មភាពជាក់លាក់ និងឆ្លើយតបចំពោះចំណុចរាំងស្ទះសំខាន់ៗ ដូចជា ក្របខ័ណ្ឌច្បាប់ និងគតិយុត្ត ហេដ្ឋារចនាសម្ព័ន្ធ ICT ជំនាញឌីជីថល និងការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមជាដើម។ រួមជាមួយនឹងគម្រោង Go4eCAM និងភាពជាដៃគូដ៏រឹងមាំក្នុងប្រទេស ខ្ញុំជឿជាក់យ៉ាងមុតមាំថា កម្ពុជានឹងមានប្រព័ន្ធអេកូឡូស៊ីដ៏អំណោយផលមួយ ដែលចាំបាច់សម្រាប់លើកកម្ពស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បង្កើនការប្រកួតប្រជែងសម្រាប់ការនាំចេញ ជំរុញសហគ្រិនភាព និងទាញប្រយោជន៍ពីប្រភពកំណើនថ្មីៗ ក្នុងយុគសម័យឌីជីថល។»

**PRESS RELEASE**

**NEW E-COMMERCE GRANTS, TRAINING SET TO BOOST CAMBODIA'S SMALL AND MEDIUM ENTERPRISES**

**Phnom Penh, 28 December 2020** – 125 small and medium sized businesses are set to gain grants and training in online commerce through a new $500,000 investment from the Ministry of Commerce of the Kingdom of Cambodia, the Enhanced Integrated Framework (EIF) and the UN Development Programme (UNDP).

The funds will fuel an innovative six-month incubation and training initiative and small grants programme to help small and medium sized enterprises move online, sell online, and, for some, sell to overseas customers through a new online marketplace (B2B2C) being developed by the Ministry of Commerce (MoC). A quota is reserved for businesses owned by women and businesses based outside of Phnom Penh.

This joint initiative by the Ministry of Commerce (MoC) and UNDP will form one of the key components of Cambodia's e-commerce acceleration project called Go4eCAM that aims to boost domestic and international opportunities for small and medium enterprises through a digital platform and create over 10,000 new jobs by 2022 as the one of the main objectives of Go4eCAM.

Cambodia's e-commerce sector has grown exponentially in the last decade and the enhanced support comes as the COVID-19 pandemic has forced many more businesses to move online. E-commerce and digitization are seen as crucial to ensure a full, rapid and sustained economic recovery for the country.

The Royal Government of Cambodia, particularly the Ministry of Commerce, has stepped up efforts in recent years to strengthen the country's e-commerce ecosystem including regulatory framework and strategy, such as passing the landmark 2019 E-commerce Law, a set of sub-decree and prakas to ease registration for e-commerce-based businesses, the Consumer Protection Law to protect the rights of online shoppers and businesses, and the recently launched E-commerce Strategy.

In support of Cambodia's response to COVID-19, UNDP is working to reskill workers, support the onboarding of 1000 small and medium sized business into the e-commerce market and promote the adoption of e-commerce across the country through an advocacy campaign to create a robust regulatory environment with support from the Government of Australia.

"The Go4eCAM project is launching at the right time, coinciding with the approval of the e-commerce law and the launch of the e-commerce strategy. The project will provide many other benefits, including increasing productivity, innovation, business expansion and job creation in Cambodia," said **H.E. Pan Sorasak**, Minister of Commerce at the launch of E-commerce Strategy.

"Cambodia's new e-commerce strategy, combined with the right incentives and investments, could be a game-changer to propel inclusive growth in the recovery from COVID-19. Inclusive investment in people, in skills development and in digital infrastructure for everyone are absolutely crucial," said **Nick Beresford**, UNDP Resident Representative.

"Cambodia's e-commerce sector is rapidly moving forward, driven further by businesses moving online to mitigate the impact of COVID-19. As an EIF contributor and through our projects that

support e-commerce regulatory acceleration and uptake, Australia is helping equip Cambodians with the necessary tools and skills to compete in this new economy, ensuring that Cambodia's digital future will be inclusive", said **H.E. Kang Pablo**, Australian Ambassador to Cambodia.

"Cambodia has great potential on e-Commerce. The recently launched e-Commerce strategy, supported by the EIF, with concrete plan of action will tackle bottleneck in critical areas, such as the legal and regulatory framework, ICT infrastructure, digital skills and SME support. Together with the Go4eCAM project and strong partnership on the ground, I strongly believe that Cambodia is putting in place a conductive ecosystem necessary to boost e-Commerce, export competitiveness, promote entrepreneurship and tap into new sources of growth in the digital era", said **Dr. Ratnakar Adhikari**, Executive Director, Executive Secretariat for the EIF at the WTO.

*For media inquiries or interviews, please contact:*

*Mr. CHEA Laichea, Acting Director of Department of International Cooperation, Ministry of Commerce via chealaichea@gmail.com*

*Mr. Samruol Im, Head of Communications at UNDP Cambodia via samruol.im@undp.org*